បណ្ណាគារភក្តីច្បាប់
PHEAKDEYLAW BOOK STORE

លេខ : ០២ អនក្រ.បក

# អនុក្រឹត
# ស្តីពី
# ការប្រើប្រាស់គណនី
# ឯកជនភាវូបនីយកម្ម
# ១៩៩៧

ផលិតជាសៀវភៅអេឡិចត្រូនិចដោយបណ្ណាគារភក្តីឡូ

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ០២ អនក្រ.បក**

**ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម**

**សហគ្រាសសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទ នៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការ គ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហ គ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាជួសជុល និង សាងសង់ធារាសាស្ត្រក្នុងប្រព័ន្ធស្រោចស្រពកំពង់ទួល ទឹកថ្លាដែលមានទឹកប្រាក់ប្រមាណ ២.៤០០.០០០ USD (ពីរលានបួន រយពាន់ដុល្លារអាមេរិក) ។ ចំនួនទឹកប្រាក់ពិតប្រាកដ និងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *